ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## នៃគណៈកម្មការមូលបត្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី មូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

## ស ម្រេ ច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា សរសេរកាត់ថា **គ.ម.ក.** ។

### ជំពូកទី ២
### តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃគណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ២.-**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ អគ្គនាយកនៃ **គ.ម.ក.** មាន មុខងារ និងភារកិច្ចបន្ថែម ដូចតទៅ ÷

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **គ.ម.ក.**
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រជូនប្រធាន និងសមាជិកនៃ **គ.ម.ក.** ដើម្បីពិនិត្យ និងសម្រេច
- ចុះកិច្ចសន្យា និងអនុសញ្ញាផ្សេងៗ ក្នុងនាម **គ.ម.ក.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.**
- ជាតំណាងរបស់ **គ.ម.ក.** ក្នុងទំនាក់ទំនងជាមួយតតីយជន ដូចជាស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជននានា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យមូលបត្រ
- ជាតំណាងឱ្យ **គ.ម.ក.** នៅចំពោះមុខតុលាការ
- រៀបចំកិច្ចប្រជុំរបស់ **គ.ម.ក.**
- គ្រប់គ្រងចំណូល និងចំណាយរបស់ **គ.ម.ក.**
- ផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនប្រធាន និងសមាជិកនៃ **គ.ម.ក.** ដើម្បីពិនិត្យ និងសម្រេច

- អនុវត្តការងារផ្សេងៗទៀត ទៅតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។

**មាត្រា ៣.–**

អគ្គនាយកនៃ **គ.ម.ក.** មានឋានៈ និងបុព្វសិទ្ធិស្មើ រដ្ឋលេខាធិការ ។ អគ្គនាយកនៃ **គ.ម.ក.** មានអគ្គនាយករងនៃ **គ.ម.ក.** មួយចំនួនជាជំនួយការតាមការចាំបាច់ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ អនុរដ្ឋលេខាធិការ ។ អគ្គនាយករងនៃ **គ.ម.ក.** មានសិទ្ធិ អំណាច និងបំពេញភារកិច្ចទាំងឡាយដែលអគ្គនាយកនៃ **គ.ម.ក.** ប្រគល់ឱ្យ ។

**មាត្រា ៤.–**

អគ្គនាយកនៃ **គ.ម.ក.** អាចមានអ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស ។

**មាត្រា ៥.–**

**គ.ម.ក.** មាននាយកដ្ឋានចំណុះចំនួន ០៦ (ប្រាំមួយ) ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម ÷

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់-ទំនងអន្តរជាតិ

៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៦. នាយកដ្ឋានកិច្ចការគតិយុត្ត

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១ (មួយ)រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ និងមានការិយាល័យចំណុះមួយចំនួនទៅតាមតម្រូវការចាំបាច់ ដែលរៀបចំឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។ ប្រធាននាយកដ្ឋានត្រូវតែងតាំង ឬផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។ ការតែងតាំង ឬ ការផ្លាស់ប្តូរភារកិច្ចចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋានចុះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក.** ។

អង្គការលេខរបស់ **គ.ម.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំផែនការ និងថវិការបស់ **គ.ម.ក.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គត់ផ្គង់ និងថ្លួសជុលសម្ភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ ឬ ឯកជននានា
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ **គ.ម.ក.**
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ៧.-**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឱ្យបោះផ្សាយនៅលើទីផ្សារ

- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ៨.-**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដារគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានា ដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិច ឬ/និង តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងរបស់ក្រុមហ៊ុនស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ប្រសិនបើមានការចាំបាច់ក្នុងក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ៩.-**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ មានមុខងារ និងភារកិច្ច ដូចខាងក្រោម :

- រៀបចំបទប្បញ្ញត្តិ ឬ លក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការរបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ

- ត្រួតពិនិត្យជាក់ស្ដែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ១០.-**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷
- រៀបចំបទប្បញ្ញត្តិ ឬ លក្ខខណ្ឌតម្រូវនានាសម្រាប់ផ្ដល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**
- ពិនិត្យ និងផ្ដល់យោបល់លើសំណើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដានទូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្ដែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ

- បញ្ជូនសំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីស៊ើបអង្កេតបន្ត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ១១.-**

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័នស្វ័យនិយ័តករ
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅលើទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់ពិន័យនានាពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទរវាងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ

- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក.** ។

## ជំពូកទី ៣
## អង្គភាពសវនកម្មផ្ទៃក្នុងនៃគណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ១២.-**

**គ.ម.ក.** មានអង្គភាពសវនកម្មផ្ទៃក្នុងដែលស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវដឹកនាំដោយប្រធាន ០១ (មួយ)រូប ដែលមានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ និងមានការិយាល័យចំណុះមួយចំនួនទៀតតាមតម្រូវការចាំបាច់ដែលរៀបចំឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងត្រូវតែងតាំង ឬ ផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។

ការតែងតាំង ឬ ការផ្លាស់ប្តូរភារកិច្ចចាប់ពីថ្នាក់ក្រោមប្រធានអង្គភាពចុះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។

**មាត្រា ១៣.-**

អង្គភាពសវនកម្មផ្ទៃក្នុងរបស់ **គ.ម.ក.** មានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷

- ពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ **គ.ម.ក.** ក្នុងការិយបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឱ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ **គ.ម.ក.**
- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ **គ.ម.ក.**

- ពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃព័ត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីព័ត៌មាន និងទិន្នន័យទាំងនេះ ក្នុងកាវិយបរិច្ឆេទសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ និងបទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអ ប្រសិនបើមានកំហុស
- ពិនិត្យលើមធ្យោបាយ ក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ **គ.ម.ភ.**
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ **គ.ម.ភ.** ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការបស់ **គ.ម.ភ.** ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ភ.** អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ
- ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីធ្វើជូនប្រធាន និងសមាជិកនៃ **គ.ម.ភ.** ពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ភ.**
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ **គ.ម.ភ.** ពិនិត្យ និងសម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឱ្យបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា
- អនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ភ.** ។

## ជំពូកទី ៤
## មន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ១៤.–**

មន្ត្រីរបស់ **គ.ម.ក.** រួមមាន ÷

- មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ និង
- មន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក.** ។

**មាត្រា ១៥.–**

អគ្គនាយកនៃ **គ.ម.ក.** អាចជ្រើសរើសមន្ត្រីដែលមិនស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដើម្បីយកទៅបម្រើការងារនៅ **គ.ម.ក.** ដោយផ្អែកទៅលើតម្រូវការចាំបាច់ ។ មន្ត្រីទាំងនេះត្រូវគ្រប់គ្រងដោយលក្ខន្តិកៈរបស់ **គ.ម.ក.** និងទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក.** ។

**មាត្រា ១៦.–**

មន្ត្រីរបស់ **គ.ម.ក.** ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ។ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់នីតិសម្បទាសម្រាប់មន្ត្រីរបស់ **គ.ម.ក.** ទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ជំពូកទី ៥
## ដំណើរការរបស់គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ១៧.–**

**គ.ម.ក.** ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិចមួយដងក្នុង ០១(មួយ)ខែ ទៅតាមការអញ្ជើញរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ។ ក្នុងករណីចាំបាច់ និងបន្ទាន់ **គ.ម.ក.** អាចបើកកិច្ចប្រជុំវិសាមញ្ញ បានគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍

ដល់វិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ឬ តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក.** ឬ តាមសំណើពីសមាជិកនៃ **គ.ម.ក.** ដែលមានចំនួនយ៉ាងតិច ១ ភាគ ៣ នៃសមាជិកទាំងអស់ ។ ក្នុងករណីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** មានធុរៈ ឬ អវត្តមាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ត្រូវផ្ទេរសិទ្ធិទៅឱ្យសមាជិកណាម្នាក់ក្នុងចំណោមសមាជិកវត្តមាន ដើម្បីដឹកនាំការប្រជុំ ។ របៀបវារៈ និងឯកសារនានាសម្រាប់កិច្ចប្រជុំសាមញ្ញត្រូវផ្ញើជូនគ្រប់សមាជិកនៃ **គ.ម.ក.** យ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃប្រជុំ ។

**មាត្រា ១៨.-**

កិច្ចប្រជុំរបស់ **គ.ម.ក.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០(ហាសិប) ភាគរយនៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ ក្នុងករណីមិនគ្រប់កូរ៉ុម កិច្ចប្រជុំលើកទី២មិនតម្រូវឱ្យមានកូរ៉ុមឡើយ ។

សេចក្តីសម្រេចរបស់ **គ.ម.ក.** អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព ។

**មាត្រា ១៩.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់តាំងលេខាធិការកត់ត្រាកិច្ចប្រជុំរបស់ **គ.ម.ក.** ។ សេចក្តីសម្រេចរបស់**គ.ម.ក.** ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំ និងលេខាធិការកត់ត្រា ។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន និង សមាជិកទាំងអស់នៃ **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ ។

**មាត្រា ២០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** ត្រូវរាយការណ៍ជាប្រចាំ អំពីការអភិវឌ្ឍ គោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងបញ្ហាប្រឈមនានាក្នុងវិស័យមូលបត្រជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីជ្រាប សុំការណែនាំ ឬ សុំការសម្រេច ។

**មាត្រា ២១.–**

**គ.ម.ក.** មាននិមិត្តសញ្ញា និងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦
## ប្រភពធនធាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ២២.–**

ប្រភពធនធាន និងថវិកា របស់ **គ.ម.ក.** រួមមាន ៖

- ថវិកាជាតិដែលផ្ដល់ឱ្យ **គ.ម.ក.**
- **គ.ម.ក.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់បម្រើដល់សេចក្ដីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារៈបរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញការងារ និងភារកិច្ចរបស់ខ្លួន ។

ក្រៅពីប្រភពធនធាន និងថវិកា ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ **គ.ម.ក.** ក៏មានប្រភពធនធានផ្សេងទៀតដែលបានមកពី ៖

- ថ្លៃសេវានៃការផ្ដល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ឬ តំណាងក្រុមហ៊ុនមូលបត្រ ឬ អ្នកចូលរួមផ្សេងទៀតក្នុងទីផ្សារមូលបត្រ ថ្លៃសេវានៃការដាក់ពាក្យសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ថ្លៃសេវានៃប្រតិបត្តិការជួញដូរមូលបត្រក្នុងទីផ្សារមូលបត្រ និងចំណូលពីប្រតិបត្តិការផ្សេងៗទៀតដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់**គ.ម.ក.** ។ កម្រៃសេវាទាំងនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.**
- ប្រាក់ពិន័យអន្តរការណ៍លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ។

ប្រភពធនធានក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវដាក់ចូលក្នុងគណនីនៃរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**គ.ម.ក.** មានសិទ្ធិទទួល និងគ្រប់គ្រងជាកម្មសិទ្ធិករនូវចលនវត្ថុ និងអចលនវត្ថុដែលជាអំណោយ ឬ អច្ច័យទានរបស់ឯកជន និងអំណោយរបស់រដ្ឋ ។

**មាត្រា ២៣.-**

**គ.ម.ក.** ត្រូវរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនទៅតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ដោយរាប់បញ្ចូលទាំងគម្រោងថវិកាលំអិតសម្រាប់ឆ្នាំនីមួយៗ ដាក់ជូនប្រធាន និងសមាជិកនៃ **គ.ម.ក.** ដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា ២៤.-**

លាភការរបស់ប្រធាន និងសមាជិកនៃ **គ.ម.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៥.-**

ប្រាក់បៀវត្ស និងលាភការ សម្រាប់មន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក.** និងទីប្រឹក្សាបច្ចេកទេសបម្រើការងារនៅ **គ.ម.ក.** និងប្រាក់បំណាច់បន្ថែមរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈរបស់ **គ.ម.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក.** ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ២៧
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធអនុក្រឹត្យលេខ.....៩៧អ......អនក្រ.បក**
**ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា**
**ចុះថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០០៨**
**អង្គការលេខរបស់គណៈកម្មការមូលបត្រកម្ពុជា**

